ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

លេខ ១៣៥ បទ.ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងាររៀបចំគោលនយោបាយ
# អភិវឌ្ឍន៍វិស័យប្រៃសណីយ៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៤៧ អនក្រ/បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការបង្កើតប្រៃសណីយ៍កម្ពុជា ជាសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ/បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**ប្រការ១:**

ត្រូវបានបង្កើតក្រុមការងាររៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឯក វណ្ណឌី** | រដ្ឋលេខាធិការ | ប្រធាន |
| ២-លោកជំទាវ | **ប្រាក់ ច័ន្ទណាយ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម | **ចាយ ណារិទ្ធ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤-លោកជំទាវ | **លិម លឿង** | ទីប្រឹក្សាក្រសួង ប.ទ | សមាជិក |
| ៥-ឯកឧត្តម | **អោក មូរ៉ា** | អគ្គនាយកប្រៃសណីយ៍កម្ពុជា | សមាជិក |
| ៦-លោក | **ព្រាប សុរិទ្ធី** | អនុប្រធានវិទ្យាស្ថានជាតិ | សមាជិក |
| ៧-លោក | **ហួត ចាន់យ៉ារ៉េត** | អគ្គនាយករង ប.ទ | សមាជិក |
| ៨-លោកស្រី | **ទេព វ៉ូដា** | អគ្គនាយករងប្រៃសណីយ៍កម្ពុជា | សមាជិក |
| ៩-លោក | **អ៊ុច សុខុម** | ប្រធាននា.គោលន.ប ប្រៃសណីយ៍ | សមាជិក |
| ១០-លោកស្រី | **មួន មួយទៀង** | ប្រធាននា.ត្រួតពិនិត្យប្រៃសណីយ៍ | សមាជិក |
| ១១-លោក | **ហ៊ីង លីហៃ** | ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ | សមាជិក |
| ១២-លោក | **ថាច់ សំ** | អនុប្រធាននា.គោលន.បប្រៃសណីយ៍ | សមាជិកអចិន្ត្រៃយ៍ |
| ១៣-លោក | **គ្រុយ សុខា** | អនុប្រធាននា.គោលន.ប ប្រៃសណីយ៍ | សមាជិក |

| | | | |
|---|---|---|---|
| ១៤-លោក | **ប៉ុល ស៊ីគីដា** | អនុប្រធាននា.គោលន.ប ប្រៃសណីយ៍ | លេខាធិការ |
| ១៥-លោក | **នាក់ ឆា** | ប្រធានការិ.ត្រួតពិនិត្យប្រៃសណីយ៍ | លេខាធិការ |

**ប្រការ២:_**

ក្រុមការងាររៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ មានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ រៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍
- កសាងគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ដោយសហការជាមួយបណ្តាក្រសួង ស្ថាប័ន វិស័យឯកជន និងផ្នែកពាក់ព័ន្ធនានា
- ពិគ្រោះយោបល់ និងផ្សព្វផ្សាយ រាល់គោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ទៅដល់គ្រប់ក្រសួង ស្ថាប័ន វិស័យឯកជន ពាក់ព័ន្ធនានា
- ប្រជុំពិភាក្សា វាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍
- ធ្វើការកែសម្រួលគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ប្រកបដោយគុណភាពខ្ពស់ ស្របតាមស្តង់ដាអន្តរជាតិ
- ប្រមូលផ្តុំព័ត៌មាន និងធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ជូនថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ៣:_**

អនុប្រធាន និងសមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធាន មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ដែលមានការពាក់ព័ន្ធ ឲ្យចូលរួមកិច្ចប្រជុំក្នុងករណីចាំបាច់។

**ប្រការ៤:_**

ថវិកាសម្រាប់ចំណាយក្នុងការបំពេញភារកិច្ចរបស់ក្រុមការងារ ជាបន្ទុករបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ៥:_**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គាធិការ ប្រធានបញ្ញត្តិករទូរគមនាគមន៍កម្ពុជា អគ្គនាយកប្រៃសណីយ៍កម្ពុជា ប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន គ្រប់ប្រធាននាយកដ្ឋាន គ្រប់ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត ក្រោមឱវាទក្រសួង អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

ប្រាក់_សុខុន

**ចម្លងជូន**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គ្រប់ថ្នាក់ដឹកនាំក្រសួង ប.ទ
-គ្រប់អង្គភាពក្រោមឱវាទក្រសួង ប.ទ
" ដើម្បីជូនជ្រាប និងសហការ "
-ដូចប្រការ៥ "ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ